**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.០០០ ហិកតា ស្ថិតនៅឃុំឈូកខ្សាច់ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.០០០ (ប្រាំបីពាន់) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិឧស្សាហកម្ម (ដាំកៅស៊ូ) ដូចមានក្នុងផែនទី និងនិយាមកាលេខ ១៤៨០ ចពលផ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ របស់សាលាខេត្តព្រះវិហារ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១២

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

## ផែនទីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន រ៉ែមដឹល ហ្វូឌីស(ខេមបូឌា) ស្ថិតនៅក្នុងស្រុកសង្គមថ្មី ខេត្តព្រះវិហារ







## ចំណុចនិយាមការផ្ទៃដីកាត់ចេញ

| N | X | Y | N | X | Y |
|---|---|---|---|---|---|
| 1 | 466967 | 1500223 | 34 | 482283 | 1497680 |
| 2 | 468517 | 1502880 | 35 | 482404 | 1497763 |
| 3 | 470267 | 1501195 | 36 | 482753 | 1497711 |
| 4 | 472338 | 1500913 | 37 | 482762 | 1497020 |
| 5 | 473000 | 1499327 | 38 | 482420 | 1496921 |
| 6 | 472647 | 1498063 | 39 | 482121 | 1497070 |
| 7 | 471884 | 1498326 | 40 | 481513 | 1496661 |
| 8 | 472010 | 1498826 | 41 | 480877 | 1496561 |
| 9 | 470712 | 1499418 | 42 | 480526 | 1496644 |
| 10 | 470256 | 1498689 | 43 | 480075 | 1496434 |
| 11 | 469412 | 1498570 | 44 | 478693 | 1496654 |
| 12 | 467933 | 1499122 | 45 | 478383 | 1496762 |
| 13 | 472316 | 1504434 | 46 | 477580 | 1496715 |
| 14 | 474779 | 1503292 | 47 | 477223 | 1496987 |
| 15 | 475027 | 1502709 | 48 | 476871 | 1497518 |
| 16 | 474923 | 1502064 | 49 | 476762 | 1497873 |
| 17 | 474094 | 1500967 | 50 | 476301 | 1497850 |
| 18 | 473573 | 1501612 | 51 | 476199 | 1497994 |
| 19 | 474308 | 1502414 | 52 | 476350 | 1498444 |
| 20 | 473816 | 1502591 | 53 | 477142 | 1498366 |
| 21 | 473590 | 1503611 | 54 | 477149 | 1497918 |
| 22 | 472729 | 1502900 | 55 | 477953 | 1498152 |
| 23 | 472293 | 1503260 | 56 | 478713 | 1499907 |
| 24 | 472502 | 1503745 | 57 | 480090 | 1499703 |
| 25 | 480498 | 1500443 | 58 | 480334 | 1500263 |
| 26 | 481526 | 1500166 | 59 | 485404 | 1497083 |
| 27 | 481071 | 1499477 | 60 | 485107 | 1497866 |
| 28 | 481608 | 1498680 | 61 | 485101 | 1498510 |
| 29 | 481386 | 1498361 | 62 | 484349 | 1494144 |
| 30 | 480992 | 1498508 | 63 | 469142 | 1505062 |
| 31 | 480949 | 1497787 | 64 | 471008 | 1504193 |
| 32 | 481319 | 1497861 | 65 | 471356 | 1504879 |
| 33 | 481556 | 1497873 | 66 | 475787 | 1502825 |
| 34 | 482283 | 1497680 | 67 | 476362 | 1502559 |

